**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០២៥សណ១៦អអក

ភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៦

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈលើគម្រោងកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី របស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង សម្រាប់ការលក់អគ្គិសនីដុំ ចេញពីបណ្តាញបញ្ជូនរង សម្រាប់ឆ្នាំ ២០១៦

អាជ្ញាធរអគ្គិសនីកម្ពុជាសូមជម្រាបជូន **អ្នកកាន់អាជ្ញាប័ណ្ណ** និង **អ្នកប្រើប្រាស់អគ្គិសនីដុំ** ដែលទិញអគ្គិសនីដុំពីបណ្តាញបញ្ជូនរង ដែលមានប្រភពពីបណ្តាញជាតិ របស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងទាំងឡាយ ឲ្យបានជ្រាបថា យោងតាមការកំណត់នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី និងយោងតាមការពិនិត្យវិភាគថ្លៃអគ្គិសនីចេញពីអនុស្ថានីយ និងចេញពីបណ្តាញបញ្ជូនរង ដែលបានធ្វើការគណនានៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ស្របទៅតាមគោលការណ៍កំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវ នៃចំណាយក្នុងអាជីវកម្មអគ្គិសនី និងបទប្បញ្ញត្តិនានា អាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងនឹងកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី របស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងទាំងឡាយ សម្រាប់ការលក់អគ្គិសនីដុំចេញពីបណ្តាញបញ្ជូនរង ដែលមានប្រភពពីបណ្តាញជាតិរបស់អគ្គិសនីកម្ពុជា តាមប្រភេទអតិថិជន និងអត្រាថ្លៃលក់អគ្គិសនី សម្រាប់ឆ្នាំ២០១៦ ដូចខាងក្រោម ៖

## ១- សម្រាប់ការលក់អគ្គិសនីឲ្យអ្នកកាន់អាជ្ញាបណ្ណចែកចាយ ចេញពីបណ្តាញបញ្ជូនរង ប្រភពពីបណ្តាញជាតិបញ្ជូនអគ្គិសនី

| លក្ខខណ្ឌ | អត្រាថ្លៃបច្ចុប្បន្ន | អត្រាថ្លៃថ្មី |
|---|---|---|
| សម្រាប់អ្នកកាន់អាជ្ញាបណ្ណ ដែលទិញប្រភពអគ្គិសនីតាមតង់ស្យុងមធ្យម MV ពីបណ្តាញបញ្ជូនរង របស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង | 0.1510 $US / kWh | 0.1470 $US / kWh |
| សម្រាប់អ្នកកាន់អាជ្ញាបណ្ណដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងដែរ ប៉ុន្តែទិញតាមនាឡិកាស្ទង់ LV ក្រោមត្រង់ស្វូ MV/LV និងបានវិនិយោគដាក់ត្រង់ស្វូ នាឡិកាស្ទង់ LV និងខ្សែតង់ស្យុងទាប LV ដោយខ្លួនឯង | 0.1560 $US / kWh | 0.1520 $US / kWh |
| សម្រាប់អ្នកកាន់អាជ្ញាបណ្ណដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរង របស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងដែរ ប៉ុន្តែទិញតាមនាឡិកាស្ទង់ LV និងខ្សែតង់ស្យុងទាប LV ក្រោមត្រង់ស្វូ MV/LV ដែលបានវិនិយោគដោយ "អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន" | 0.1660 $US / kWh | 0.1620 $US / kWh |

## ២- សម្រាប់ការលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ឧស្សាហកម្ម ពាណិជ្ជកម្ម ចេញពីបណ្តាញបញ្ជូនរង ប្រភពពីបណ្តាញជាតិបញ្ជូនអគ្គិសនី

| លក្ខខណ្ឌ | អត្រាថ្លៃបច្ចុប្បន្ន | អត្រាថ្លៃថ្មី |
|---|---|---|
| សម្រាប់អ្នកប្រើប្រាស់អគ្គិសនី ដែលបានទិញអគ្គិសនីពីបណ្តាញបញ្ជូនរង របស់ "អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនរងឯកជន" តាមនាឡិកាស្ទង់ MV | 0.1700 $US / kWh | 0.1675 $US / kWh |

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសូមដាក់ "ឯកសារបញ្ជីថ្លៃលក់អគ្គិសនី" ថ្មីនេះ ពិគ្រោះយោបល់ជាសាធារណៈ ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកទិញអគ្គិសនីដុំទាំងអស់ ដែលឋិតនៅក្នុងប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ។ ក្រោយថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ "ឯកសារបញ្ជីថ្លៃលក់អគ្គិសនី" ថ្មីនេះ នឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាមានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនី និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកទិញអគ្គិសនីដុំផង និងធ្វើសេវាបញ្ជូនរងផង ។ ឯកសារគណនាបញ្ជីថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ ---------------------------------------------------------------------- សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកទិញអគ្គិសនីដុំទាំងអស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ ដល់អាជ្ញាធរអគ្គិសនីកម្ពុជាលើ "ឯកសារបញ្ជីថ្លៃលក់" ថ្មីនេះ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**